FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៦ លេខ ៥៦ ខែមករា ឆ្នាំ ២០០៧

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ចំណាត់ថ្នាក់សមត្ថភាពដីបាសាល់នៃប្រទេសកម្ពុជា

អត្ថបទស្រាវជ្រាវនេះ សម្រាប់ជួយឲ្យមន្ត្រីផ្សព្វផ្សាយ និងអ្នកក្សេត្រសាស្ត្រទាំងឡាយចេះធ្វើអត្តសញ្ញាណ និងធ្វើចំណាត់ថ្នាក់ដីសំខាន់ៗ និងកត្តាកំណត់ដីជាតិផ្សេងៗដែលទាក់ទិននឹងដីសម្រាប់ផលិតកម្មដំណាំនៅលើដីបាសាល់។ វាមានការពាក់ព័ន្ធទៅនឹងផលិតកម្មដំណាំខ្ពង់រាបនៅលើដីបាសាល់ ដែលមាននៅខេត្តកំពង់ធំ កំពង់ចាម និងក្រចេះ នាភាគខាងកើតនៃប្រទេសកម្ពុជា។ ដោយផ្អែកទៅលើប្រភេទដីនៅក្នុងស្រុកអូរាំងឪនៃខេត្តកំពង់ចាម យើងបានវាយតម្លៃសមត្ថភាពនៃដីសម្រាប់ដំណាំចម្ការ នៅលើដីបាសាល់។ សក្តានុពលនៃផ្ទៃដីសម្រាប់ធ្វើពិពិធកម្មដំណាំខ្ពង់រាបនៅលើដីបាសាល់ គឺស្ថិតនៅក្នុងក្រុមសណ្ឋានដីដែលតាងដោយ KC1, KC2 និង KC3 (មើលដ្យាក្រាមខាងក្រោម)។

**ឯកតាសណ្ឋានដីបាសាល់៖** ដ្យាក្រាមខាងក្រោម បង្ហាញអំពីទំនាក់ទំនងគ្នានៃដី KC1, KC2 និង KC3 និងការវាយតម្លៃទំនាក់ទំនងរបស់វានៅក្នុងសណ្ឋានដីបាសាល់។




**KC1 ក្រុមដី ឡាបានសៀក**
ជាដីខ្ពង់រាបលើដីបាសាល់ មានសណ្ឋានខ្ពស់ទាបៗ ឬរលកខ្សោយទៅមធ្យម ជាដីឥដ្ឋពណ៌ក្រហម។ ជាទូទៅ ត្រូវបានគេប្រើប្រាស់សម្រាប់ដំណាំកៅស៊ូ។ ជាដីមានជម្រៅជ្រៅ ប្រកបដោយរចនាសម្ព័ន្ធជាគ្រាប់មូលតូចៗ និងដីស្រទាប់ក្រោមជាដីឥដ្ឋ។







**KC2 ក្រុមដី អូរាំងឪ**
ជាដីជាយនៃខ្ពង់រាបបាសាល់ ដែលមានចំណោតពីតិចទៅបង្គួរ និងជាទីទួលដីបាសាល់ទាបៗ។ ដីមានពណ៌ត្នោត ឬក្រហម ដែលមានថ្ម ឬគ្រួស។ សណ្ឋានដីនេះខ្ពស់ជាង និងចោតជាងដីកំពង់សៀម។ ជានិច្ចកាល វាតែងតែជ្រោះទឹកពេកដែលមិនអនុគ្រោះចំពោះដំណាំស្រូវ ប៉ុន្តែអនុគ្រោះចំពោះដំណាំចម្ការ។ ផ្ទៃដីខាងលើមានពណ៌ត្នោតជាងដីកំពង់សៀម ប៉ុន្តែជាធម្មតាវាមានពណ៌ក្រហមនៅផ្ទៃខាងក្រោម។ វាសម្បូរទៅដោយបំណែកនៃគ្រាប់ក្រួសពណ៌ក្រហមត្នោត ទំហំមធ្យមទៅធំ។




**KC3 ក្រុមដី កំពង់សៀម**
ជាតំបន់ដែលមានចំណោតខ្សោយខ្លាំង ស្ថិតនៅជុំវិញតំបន់ខ្ពង់រាបបាសាល់។ ជាដីឥដ្ឋពណ៌ខ្មៅទៅប្រផេះក្រមៅ ដែលកើតមាននៅលើដីវាលរាប ឬចំណោតជើងភ្នំ។ ជាទូទៅ នៅរដូវប្រាំងតែងមានស្នាមប្រេះក្រហែងធំៗហើយជ្រៅនៅពីលើដីឥដ្ឋស្រទាប់ក្រោម។ នៅឯទីជម្រៅអាចនឹងមានផ្ទាំងថ្មបាសាល់ធំៗ។ ជាដីដាំដុះដំណាំស្រូវ និងដំណាំចម្ការ។

**តារាងទី ១៖ តារាងវាយតម្លៃចំណាត់ថ្នាក់សម្ថភាពនៃដីផ្អែកលើការវាយតម្លៃគុណភាពដី ដើម្បីផលិតកម្មដំណាំចម្ការ**

ដីមានចំណាត់ថ្នាក់សម្ថភាពខ្ពស់ខ្លាំង ជាដីដែលគ្មានកត្តារាំងសំខាន់ៗក្នុងការប្រើប្រាស់វា។ ចំណែកចំណាត់ថ្នាក់សម្ថភាពទាប គឺមានសក្តានុពលក្នុងការប្រើប្រាស់ទាប ដោយសារកត្តារាំងជាច្រើន ដែលធ្វើឲ្យទិន្នផលដំណាំធ្លាក់ចុះ។ សមត្ថភាពទាបណាស់ ជាដីដែលមានកត្តារាំងច្រើនពេក ការប្រើប្រាស់ដីនេះមិនត្រូវបានផ្តល់ជាអនុសាសន៍ឡើយ។

| ចំណាត់ថ្នាក់ គុណភាពដី | ថ្នាក់លេខ ១ សមត្ថភាពខ្ពស់ខ្លាំង | ថ្នាក់លេខ ២ សមត្ថភាពខ្ពស់ | ថ្នាក់លេខ ៣ សមត្ថភាពមធ្យម | ថ្នាក់លេខ ៤ សមត្ថភាពទាប | ថ្នាក់លេខ ៥ សមត្ថភាពទាបណាស់ |
|---|---|---|---|---|---|
| លទ្ធភាពនៃការរៀបចំ | ល្អ ឬមធ្យម | | ខ្សោយ | | ខ្សោយណាស់ |
| ស្ថានភាពផ្ទៃដីខាងលើ | ផុស ឬទន់ ឬរឹងល្មម ស្វ័យការពាររំហួត ឬសំណឹក | មានថ្មតិចតួច | ក្រៀម និងមានថ្មមធ្យម | រឹង មានថ្មច្រើន | មានថ្មច្រើនណាស់ |
| ភាពងាយបាត់បង់ទម្រង់ដីនៅផ្ទៃខាងលើ | ទាប | មធ្យម | ខ្ពស់ | | |
| pH ($CaCl_2$) | 5 - 7.5 | 4.6 - 5 | 4.3 - 4.5 | <4.3 ឬ >8.5 | |
| កម្រិតសារធាតុចិញ្ចឹម | ការរិចរិលដោយការហូរច្រោះចុះក្រោមមានកម្រិតទាប | ការរិចរិលដោយការហូរច្រោះចុះក្រោមមានកម្រិតមធ្យម | ការរិចរិលដោយការហូរច្រោះចុះក្រោមមានកម្រិតខ្ពស់ | | |
| ភាពជាំទឹក | គ្មាន ឬតិចណាស់ | តិច | មធ្យម | | ខ្ពស់ ឬខ្ពស់ណាស់ |
| ការលិចទឹកជំនន់ | គ្មាន ឬតិចតួច | | មធ្យម | | ខ្ពស់ |
| សមត្ថភាពរក្សាទឹករបស់ដី (មម/ម) | >70 | 35 - 50 | 35 - 50 | <35 | |
| ជម្រៅនៃការចាក់ឫស (សម) | >50 | 35 - 50 | 25 - 35 | 15 - 25 | <15 |
| ហានិភ័យនៃការហូរច្រោះដោយទឹក | តិច | មធ្យម | ខ្ពស់ | ខ្ពស់ណាស់ | ខ្ពស់បំផុត |
| ការបាត់បង់ធាតុផូស្វ័រ | តិច | មធ្យម | ខ្ពស់ | | |

គំនូសបំព្រួញនៃដំណើរការធ្វើចំណាត់ថ្នាក់សមត្ថភាពដី សម្រាប់ផលិតកម្មដំណាំ។ សមត្ថភាពនៃដី ចំពោះផលិតកម្មដំណាំខ្លង់រាប អាចត្រូវបានវាយតម្លៃតាមលក្ខណៈដី (វិធីទី ១) ឬតាមប្រភេទដី (វិធីទី ២)។




## លក្ខណៈសំខាន់ៗនៃក្រុមដីអូរាំងឪ ដែលមានឥទ្ធិពលលើចំណាត់ថ្នាក់សមត្ថភាពរបស់វាសម្រាប់ផលិតកម្មដំណាំចម្ការ

| លក្ខណៈដី | ការវាយតម្លៃ | សមត្ថភាព |
|---|---|---|
| លទ្ធភាពនៃការរៀបចំដី | ខ្សោយ | មធ្យម |
| ស្ថានភាពផ្ទៃដីខាងលើ | មានភាពរឹង មានគម្របដោយខ្លួនឯង | ខ្ពស់ណាស់-មធ្យម |
| ភាពងាយបាត់បង់ទម្រង់ដីនៅផ្ទៃខាងលើ | មធ្យម | ខ្ពស់ |
| pH ($CaCl_2$) (0-20 cm) | 4.5 ទៅ >5 | ខ្ពស់ណាស់-ខ្ពស់ |
| pH ($CaCl_2$) (20-50 cm) | 4.3 ទៅ >5 | ខ្ពស់ណាស់-មធ្យម |
| កម្រិតសារធាតុចិញ្ចឹម | ការិចរិលដោយការហូរច្រោះចុះក្រោម មានកម្រិតពីមធ្យមទៅខ្ពស់ កម្រិតរក្សាផូស្វ័រពីមធ្យមទៅខ្ពស់ ភាពជូរមានកម្រិតមធ្យម | ខ្ពស់ |
| ភាពជាំទឹក | ទាប | ខ្ពស់ |
| សមត្ថភាពរក្សាទឹកទុករបស់ដី (មម/ម) | < 35 | មធ្យម |
| ហានិភ័យនៃការហូរច្រោះដោយទឹក | មធ្យម | ខ្ពស់ |
| សមត្ថភាពជាទូទៅនៃដី | ការផ្ទុកទឹកក្នុងដីមានកម្រិតទាប | មធ្យម |

ជាដីដែលច្រោះទឹកខ្លាំង មានជម្រៅជ្រៅបង្គួរទៅរាក់ និងមានការផ្ទុកទឹកក្នុងដីបានតិចតួច ដោយសាមានក្រួសច្រើននៅក្នុងដីស្រទាប់ក្រោម។ ដំណាំដែលងាយរងគ្រោះដោយសារការរាំងស្ងួតនៅលើដីនេះ ដូចជាសណ្តែកសៀងជាដើម តែងតែផ្តល់ទិន្នផលទាប ប្រសិនបើគ្មានទឹកភ្លៀងគ្រប់គ្រាន់ និងទៀងទាត់នោះទេ។ ទិន្នផលដំណាំនៅលើដីនេះអាចមានការប្រែប្រួលខ្លាំងពីមួយរដូវទៅមួយរដូវ អាស្រ័យលើបរិមាណ និងរបាយទឹកភ្លៀង ដីប្រភេទនេះឆាប់រឹងនៅពេលស្ងួត ហើយបង្កើតឲ្យមានស្រទាប់ក្រោមនៅលើផ្ទៃដីដែលនាំឲ្យមានការលំបាកក្នុងការភ្ជួររាស់ដីនាដើមរដូវវស្សា ហើយដំណាំនៅលើដីនេះក៏មានការលំបាកក្នុងការដុះចេញមកដែរ។ ភាពជូរនៃដីស្រទាប់ក្រោម អាចរាំងការលូតលាស់របស់ឫសនៅកន្លែងខ្លះ។ មានការហូរច្រោះនៃសារធាតុចិញ្ចឹមចុះទៅក្រោមជាបង្គួរ ប៉ុន្តែដីប្រភេទនេះមានកម្រិតផូស្វ័រខ្ពស់។ នៅតាមទីចំណោតត្រូវគ្រប់គ្រងឲ្យបានល្អដើម្បីចៀសវាងការហូរច្រោះដោយទឹក។

## លក្ខណៈសំខាន់ៗនៃក្រុមដីឡាបានសៀក ដែលមានឥទ្ធិពលលើចំណាត់ថ្នាក់សមត្ថភាពរបស់វាសម្រាប់ផលិតកម្មដំណាំចម្ការ

| លក្ខណៈដី | ការវាយតម្លៃ | សមត្ថភាព |
|---|---|---|
| pH ($CaCl_2$) (0-20 cm) | 4.3 - 4.5 | មធ្យម |
| pH ($CaCl_2$) (20-50 cm) | 4.3 - 4.5 | មធ្យម |
| កម្រិតសារធាតុចិញ្ចឹម | អាស៊ីតខ្លាំង ការហូរច្រោះចុះក្រោមមធ្យម កម្រិតរក្សាផូស្វ័រខ្ពស់ | ខ្ពស់ |
| ហានិភ័យ និងការហូច្រោះដោយទឹក | មធ្យម | ខ្ពស់ |
| សមត្ថភាពជាទូទៅនៃដី | pH ទាប | មធ្យម |

ជាដីដែលច្រោះទឹកខ្លាំង មានជម្រៅជ្រៅ មានសមត្ថភាពរក្សាទឹកទុកក្នុងដីបានល្អ ប៉ុន្តែការលូតលាស់នៃឫស និងការស្រូបទឹក និងសារធាតុចិញ្ចឹមអាចមានឧបសគ្គដោយភាពជូរនៃដី។ សមត្ថភាពនៃដីនេះ មានការប្រែប្រួលអាស្រ័យលើភាពជូរនៃដី។ កន្លែងដែលមានតម្លៃ pH ទាបខ្លាំង សមត្ថភាពនៃដីប្រភេទនេះមានកម្រិតទាបណាស់សម្រាប់គ្រប់ដំណាំទាំងអស់ លើកលែងតែអម្បូរដែលធន់នឹងដីជូរខ្លាំង ដូចជាដំឡូងមីជាដើម។ ចំពោះកន្លែងដែលមានតម្លៃ pH ខ្ពស់ ដីនេះមានសមត្ថភាពខ្ពស់។ នៅលើទីចំណោតដែលគ្មានសារធាតុគម្របដី ឬរុក្ខជាតិគម្របគ្រប់គ្រាន់ត្រូវគ្រប់គ្រងការរិចរិលដោយការហូរច្រោះដោយទឹកឲ្យបានល្អ។

## លក្ខណៈសំខាន់ៗនៃក្រុមដីកំពង់សៀម ដែលមានឥទ្ធិពលលើចំណាត់ថ្នាក់សមត្ថភាពរបស់វាសម្រាប់ផលិតកម្មដំណាំចម្ការ

| លក្ខណៈដី | ការវាយតម្លៃ | សមត្ថភាព |
|---|---|---|
| លទ្ធភាពនៃការរៀបចំដី | ខ្សោយ | មធ្យម |
| ភាពងាយបាត់បង់ទម្រង់ដីនៅផ្ទៃខាងលើ | មធ្យម | ខ្ពស់ |
| កម្រិតសារធាតុចិញ្ចឹម | ការហូរច្រោះចុះក្រោម មានកម្រិតទាប កម្រិតរក្សាផូស្វ័រមធ្យម | ខ្ពស់ណាស់-ខ្ពស់ |
| ភាពជាំទឹក | មធ្យម | មធ្យម |
| ជម្រៅនៃការចាក់ឫស (ស.ម) | 35 ទៅ > 50 | ខ្ពស់ណាស់-ខ្ពស់ |
| សមត្ថភាពជាទូទៅនៃដី | ជាំទឹក និងលទ្ធភាពរៀបចំដីទាប | មធ្យម |

ជាដីមានជម្រៅជ្រៅបង្គួរ ងាយដក់ទឹក ជាពិសេសនៅរដូវវស្សាដែលមានភ្លៀងធ្លាក់ច្រើន។ បម្រែបម្រួលភាពជាំទឹកកើតមានឡើងជាអន្លើៗ អាស្រ័យលើប្រព័ន្ធបង្ហូរទឹក និងភាពរាបស្មើនៃដីចម្ការ។ ដីនឹងឡើងរឹងនៅពេលស្ងួត ដែលអាចមានការលំបាកក្នុងការរៀបចំដីនៅដើមរដូវវស្សា ហើយវាបែជាស្អិតនៅពេលត្រូវទឹក ដែលផ្តល់ការលំបាកដល់ការភ្ជួររាស់ដីសម្រាប់ដាំដំណាំចម្ការ។ បណ្តាសណ្ឋានដីដែលមានរយៈកម្ពស់ទាបៗនៃក្រុមដីកំពង់សៀម (KC4, KC5) ស្ទើរតែទាំងអស់ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវ ដោយសារភាពជាំទឹក និងគ្រោះទឹកជំនន់មានកម្រិតខ្ពស់ពេកសម្រាប់ដំណាំចម្ការ។




រូបទី ១៖ កត្តាចម្បងបំផុតដែលកម្រិតនូវការលូតលាស់ដំណាំចម្ការ នៅលើក្រុមដីនានាក្នុងស្រុកអូរាំងឪ ខេត្តកំពង់ចាម។




រូបទី ២៖ សមត្ថភាពនៃដីសម្រាប់ដំណាំចម្ការនៅក្នុងស្រុកអូរាំងឪ ខេត្តកំពង់ចាម។

## សន្និដ្ឋាន

- ជាទូទៅ ក្រុមដីឡាបានសៀក អូរាំងឪ និងកំពង់សៀម មានសមត្ថភាពមធ្យមក្នុងការប្រើប្រាស់សម្រាប់ដំណាំចម្ការ។
- ក្រុមដីនីមួយៗមានកត្តាកំណត់ជីជាតិផ្សេងៗគ្នា ដែលមានឥទ្ធិពលលើការគ្រប់គ្រង និងការជ្រើសរើសមុខដំណាំដែលសមស្របបំផុត។
- ចំណាត់ថ្នាក់សមត្ថភាពនៃដីខាងលើនេះ ធ្វើឡើងផ្អែកលើការធ្វើអត្តសញ្ញាណលក្ខណៈដី ប៉ុន្តែភាពខុសគ្នាតាមទីកន្លែងដោយឡែកៗអាចកើតមានឡើង។ សមត្ថភាពនៃដីនៅលើចម្ការជាក់លាក់មួយអាចខ្ពស់ ឬទាបជាងចំណាត់ថ្នាក់ខាងលើ។
- សមត្ថភាពនៃដី អាចធ្វើការវាយតម្លៃដោយផ្អែកលើគុណភាពនៃដី នៅលើចម្ការជាក់លាក់។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិទ្យាសាស្ត្រដី ទឹក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: vseng@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh